# ការិយាល័យ វត្តមានអវត្តមាន និង ការគេចសាលា
# វិធីសាស្រ្តនៃការធ្វើអន្តរាគមន៍ (TIP) ឆ្នាំ ២០១៧/១៨

គ្រប់ថ្នាក់ (ថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ១២)




## ទិសដៅ នៃ TIP៖

- ជូនដំណឹងដល់ ឪពុកម្តាយ/អាណាព្យាបាល ដើម្បីឱ្យពួកគាត់បានដឹងអំពីអវត្តមានរបស់កូនពួកគេ។
- រកឲ្យឃើញពីមូលហេតុឫសគល់ (ឧបស័គ្គ) ដែលរារាំងសិស្សមិនអោយមកសាលារៀន។
- ឲ្យ ឪពុកម្តាយ/អាណាព្យាបាល និង/ឬ សិស្ស ចូលរួមនៅក្នុងដំណើរការនៃ ការបង្កើត និង ការអនុវត្ត ការធ្វើអន្តរាគមន៍ ដែលអាច លុប បំបាត់ ឬ កាត់បន្ថយ ឧបស័គ្គ។
- កត់ត្រាទុកនូវរាល់ ការខំប្រឹងប្រែង និង ការធ្វើអន្តរាគមន៍ (ដោយប្រើ MTSS នៅក្នុង SchoolNet (ប្រព័ន្ធសាលា)) សម្រាប់ការបញ្ជូនទៅ DHS/តុលាការផ្នែកសិស្សគេចសាលា។

**នៅគ្រប់ អវត្តមាន ឬ ការមករៀនយឺតពេល/At <u>Every</u> Absence or Lateness**

- ការហៅទូរស័ព្ទស្វ័យប្រវត្តិ បានកើតឡើងដោយការបញ្ចូល អវត្តមាន និង ការមករៀនយឺតពេល នៅក្នុង ប្រព័ន្ធព័ត៌មានសិស្ស (SIS)។

**នៅពេល អវត្តមាន ខុសច្បាប់/គ្មានមូលហេតុ លើកទី ៣/At the 3rd Illegal/Unexcused Absence**

- គេផ្ញើ លិខិតជូនដំណឹងអំពីច្បាប់នៃអវត្តមានចំនួនបី (៣) ថ្ងៃ ទៅមាតាបិតា/អាណាព្យាបាល ឬ ប្រគល់ឱ្យសិស្សយកទៅផ្ទះ។

**អវត្តមានខុសច្បាប់ពី ៦ ទៅ ៩ ដង/From the 6th to the 9th Illegal Absence**

- ចាប់ផ្តើមដំណើរការ **MTSS** ជាមួយការធ្វើអន្តរាគមន៍ដែលបានកត់ត្រាទុក នៅក្នុង SchoolNet។
- កែសម្រួល **IEP** សម្រាប់សិស្សដែលទទួលការអប់រំពិសេស ដើម្បីបង្កើតផែនការសម្រាប់ វត្តមានអវត្តមាន។

**នៅពេលអវត្តមានខុសច្បាប់លើកទី ១០/At the 10th Illegal Absence**

***(**សិស្សដែលមានអាយុក្រោម ១៧ ឆ្នាំ/***Students under the age of 17)***

- គេពិនិត្យឯកសារឡើងវិញ ហើយធ្វើការសម្រេចចិត្ត ដើម្បីបញ្ជូនសិស្សទៅ DHS/តុលាការផ្នែកសិស្សគេចសាលា។
- គេបំពេញ ទម្រង់បែបបទដើម្បីបញ្ជូនទៅតុលាការផ្នែកសិស្សគេចសាលា ដោយមានការចុះហត្ថលេខាទទួលយល់ព្រមពីនាយកសាលា។ ថ្ងៃកំណត់សម្រាប់ប្រគល់ ទម្រង់បែបបទដើម្បីបញ្ជូនទៅតុលាការផ្នែកសិស្សគេចសាលា ឲ្យទៅការិយាល័យ វត្តមានអវត្តមាន និង ការគេចសាលា គឺថ្ងៃទី ២៥ រៀងរាល់ខែ តាមរយៈទូរសារ (២១៥-៤០០-៤២២៣)។
  * សម្គាល់៖ បងប្អូនបង្កើតរបស់សិស្សគេចសាលា ដែលរៀននៅថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ៣ ត្រូវតែចុះឈ្មោះនៅក្នុងបញ្ជីនៃ សំណុំបែបបទដែលត្រូវបញ្ជូនទៅតុលាការផ្នែកសិស្សគេចសាលា ជាមួយបងប្អូនដែលមានអាយុច្រើនជាង ដែលរៀននៅថ្នាក់ទី ៤ ដល់ថ្នាក់ទី ១២។

**នៅពេលសិស្សត្រឡប់ពី តុលាការផ្នែកសិស្សគេចសាលា វិញ/Upon the Student's Return from Truancy Court**

- ពិនិត្យមើល បទបញ្ជារបស់តុលាការ រួមទាំងការចាត់ចែងសំណុំរឿង។
  * សម្គាល់៖ ការចាត់ចែង/ព័ត៌មានពីតុលាការ អាចរកបាននៅក្នុងកាឡេន *Truancy Court* នៅក្នុងប្រព័ន្ធ SIS ។
- តាមដានវត្តមានអវត្តមាន និងរក្សាទំនាក់ទំនងជាមួយ អ្នកផ្តល់ជំនួយរបស់ DHS និង អ្នកតំណាងតុលាការ របស់ក្រសួងអប់រំ។

**ច្បាប់ចម្លងនៃ លិខិតជូនដំណឹងអំពីច្បាប់នៃអវត្តមានចំនួនបីថ្ងៃ និង លិខិតបញ្ជាក់ពីអវត្តមាន ទាំងអស់ ត្រូវដាក់ទុកនៅក្នុងសំណុំឯកសារសិស្ស (*Pupil Pocket*) នៅបំណាច់ឆ្នាំសិស្សា។**

**440 N. Broad Street, Suite 243, Philadelphia, PA 19130 * 215.400.4220 (T) * 215.400.4223 (F) * attendanceandtruancy@philasd.org**